ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០៥៤ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងសារាចរលេខ ០៩ សរ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០១៥ របស់រាជរដ្ឋាភិបាលស្តីពីវិធាននិងនីតិវិធីនៃការរៀបចំការអនុវត្តការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងសេចក្តីសម្រេចលេខ ០៣៧ សសរ ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៨ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ស ម្រេ ច

**ប្រការ ១._**

កែសម្រួលក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ឆាន់ សាផាន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម **ខិម សំអ៊ែល** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. | ឯកឧត្តម **សេង ឡូត** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល | អនុប្រធានអចិន្ត្រៃយ៍ |



អាសយដ្ឋាន : ជីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

| | | |
|---|---|---|
| ៤. លោក **សេង សុវណ្ណរ័ត្ននា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល | មន្ត្រីបង្គោល |
| ៥. លោក **ម៉ុង សុខលាភ** | ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច | សមាជិក |
| ៦. លោក **កុសល សុពិនឝ្ស** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៧. លោក **អេ ម៉ុនធឿន** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៨. លោក **យ៉ួន សុជាតិ** | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៩. លោក **ទូ សូធូ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ | មន្ត្រីបង្គោល |
| ១០. លោក **ឌី ផលា** | អនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច | មន្ត្រីបង្គោល |
| ១១. លោក **អ៊ុង ចន្ទសុវណ្ណ** | ប្រធានការិយាល័យហិរញ្ញកិច្ច | សមាជិក |
| ១២. លោក **ខួន បុណ្ណមី** | ប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ១៣. លោក **ស៊ុំ សុខជាតិ** | ប្រធានការិយាល័យគ្រប់គ្រង និងផ្គត់ផ្គង់ | សមាជិក |
| ១៤. លោក **ចាន់ សុផាន់ណា** | អនុប្រធានការិយាល័យផែនការ | សមាជិក |
| ១៥. កញ្ញា **ម៉ែត ចំណាន** | អនុប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ១៦. លោក **ម៉ុត រតនៈ** | អនុប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ១៧. លោកស្រី **ពេជ្រ មរកត** | អនុប្រធានការិយាល័យហិរញ្ញកិច្ច | សមាជិក |

**ប្រការ ២.**_

ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តតួនាទី និងភារកិច្ចតាមឧបសម្ព័ន្ធ "ក" នៃប្រកាសលេខ ៣៥១ សហវ.បក ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៨ ស្តីពីវិធាន និងនីតិវិធីនៃការផ្តល់ការលើកទឹកចិត្តជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ ៣.**_

សមាជិកក្រុមការងារ និងមន្ត្រីបង្គោលត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្រុមការងារមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទឲ្យជួយការងារតាមការចាំបាច់។

**ប្រការ ៤.**_

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៥.**_

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ ១ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ